ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

terre des hommes
stops child exploitation

# អនុស្សរណៈនៃការយោគយល់

# រវាង

# គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

# និង

# អង្គការដែនដីមនុស្សហូឡង់ដ៍-ប្រចាំកម្ពុជា

# ស្តីពី

# ការទប់ស្កាត់អំពើជួញដូរ ការរំលោភបំពាន

# និងការកេងប្រវ័ញ្ចលើកុមារគ្រប់ទម្រង់

## បុព្វកថា

**ដោយហេតុថា ៖**

- គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានបង្ហាញនូវបំណងដូចបានចែងក្នុងអនុស្សរណៈនៃការយោគយល់នេះថា អង្គការដែនដីមនុស្សហូឡង់ដ៏-ប្រចាំកម្ពុជាបានចូលរួម ចំណែកការងារមនុស្សធម៌នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីលើកកម្ពស់សុខុមាលភាពសង្គមតាមរយៈការបង្ការទប់ស្កាត់ និងការឆ្លើយតបធ្វើឱ្យកាន់តែប្រសើរឡើងនូវការគោរពសិទ្ធិកុមារ និងប្រាកដថាកុមារទទួលបាននូវការការពារ។
- គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអង្គការដែនដីមនុស្សហូឡង់ដ៏ប្រចាំកម្ពុជាធ្វើកិច្ចសហការ ក្នុងការបង្ការ ទប់ស្កាត់ ការយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឬទម្រង់ណាមួយ នៃការកេងប្រវ័ញ្ចផ្សេងទៀត និងការរំលោភបំពានផ្លូវភេទលើកុមារឱ្យមានប្រសិទ្ធភាពខ្ពស់។
- គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សតាមរយៈយន្តការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងអង្គការដែនដីមនុស្សហូឡង់ដ៏ប្រចាំកម្ពុជា បានព្រមព្រៀងសហការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សដោយផ្អែកលើផែនការយុទ្ធសាស្ត្រជាតិ (គ.ជ.ប.ជ ២០១៩-២០២៣) ច្បាប់គោលនយោបាយជាតិ និងអន្តរជាតិ ព្រមទាំងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ និងកិច្ចសហបការរវាងប្រទេសកម្ពុជា និងអន្តរជាតិ ដើម្បីពង្រឹងសកម្មភាពលើកិច្ចសហប្រតិបត្តិការក្នុងការបង្ការទប់ស្កាត់ ការសង្គ្រោះ និងការផ្តល់សេវាជូនជនរងគ្រោះ។

## ផ្នែកទី១

## គោលបំណង

**ប្រការ១.** - អនុស្សរណៈនៃការយោគយល់នេះ មានគោលបំណងបង្កើនកិច្ចសហប្រតិបត្តិការ រវាងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអង្គការដែនដីមនុស្សហូឡង់ដ៏-ប្រចាំកម្ពុជា ក្នុងការរួមចំណែកទប់ស្កាត់អំពើជួញដូរ ការរំលោភបំពាន និងការកេងប្រវ័ញ្ចលើកុមារគ្រប់ទម្រង់ ជាពិសេសតាមប្រព័ន្ធអនឡាញ។

## ផ្នែកទី២

## ការទទួលខុសត្រូវរបស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ)

**ប្រការ២.** ដើម្បីឱ្យការអនុវត្តអនុស្សរណៈនេះទទួលបានជោគជ័យ និងមានប្រសិទ្ធភាពខ្ពស់ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) បានព្រមព្រៀងដូចខាងក្រោម៖

- អនុញ្ញាតឱ្យអង្គការដែនដីមនុស្សហូឡង់ដ៏-ប្រចាំកម្ពុជា បំពេញការងាររបស់ខ្លួនទៅតាមគោលការណ៍ច្បាប់ និងបទដ្ឋានគតិយុត្ត នៃព្រះរាជាណាចក្រកម្ពុជាដែលនៅជាធរមាន។
- សម្របសម្រួលឱ្យអង្គការដែនដីមនុស្សហូឡង់ដ៏-ប្រចាំកម្ពុជាបានសហការជាមួយក្រសួង-ស្ថាប័ន និងរាជធានី-ខេត្តដែលពាក់ព័ន្ធ
- ជួបប្រជុំពិភាក្សាជាទៀងទាត់លើបច្ចុប្បន្នភាព និងវឌ្ឍនភាពនៃគម្រោងរវាងអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ និងក្រុមបច្ចេកទេសអង្គការដែនដីមនុស្សហូឡង់ដ៏-ប្រចាំកម្ពុជា ។
- បើកទូលាយឱ្យអង្គការដែនដីមនុស្សហូឡង់ដ៏-ប្រចាំកម្ពុជា បានចូលរួមជាបច្ចេកទេស ធនធាន ឬសកម្មភាពដែលពាក់ព័ន្ធផ្សេងទៀតរបស់ គ.ជ.ប.ជ តាមការចាំបាច់។

K

## ផ្នែកទី៣

## ការទទួលខុសត្រូវរបស់អង្គការដែនដីមនុស្សហូឡង់ដ៏-ប្រចាំកម្ពុជា

**ប្រការ៣.** អង្គការដែនដីមនុស្សហូឡង់ដ៏-ប្រចាំកម្ពុជាក្នុងអនុស្សរណៈនេះមានភារកិច្ចដូចខាងក្រោម៖

- អនុវត្តសកម្មភាពរបស់គម្រោងឱ្យមានប្រសិទ្ធភាពចំគោលដៅ និងត្រូវគោរពឱ្យបានខ្ជាប់ខ្ជួននូវច្បាប់ និងបទប្បញ្ញត្តិទាំងឡាយរបស់ព្រះរាជាណាចក្រកម្ពុជា ក្រោមជំនួយជាថវិកាឧបត្ថម្ភដោយក្រសួងសង្គមកិច្ចរបស់ប្រទេសហូឡង់ដ៏។
- ប្រតិបត្តិនូវរាល់សកម្មភាពមនុស្សធម៌ជួយដល់កុមាររងគ្រោះនិងងាយរងគ្រោះដោយអំពើជួញដូរមនុស្សស្របតាមផែនការសកម្មភាព និងគោលនយោបាយរបស់ខ្លួនដោយប្រកាន់ខ្ជាប់នូវគោលការណ៍ នៃកិច្ចសហប្រតិបត្តិការឱ្យស្របតាមច្បាប់ នៃព្រះរាជាណាចក្រកម្ពុជា។
- មិនអនុញ្ញាតឱ្យភ្នាក់ងាររបស់ខ្លួនក៏ដូចជាអង្គការដៃគូដែលទទួលមូលនិធិពីអង្គការដែនដីមនុស្សហូឡង់ដ៏ធ្វើសកម្មភាពនយោបាយ និងមិនអនុញ្ញាតឲ្យចូលរួមនូវរាល់សកម្មភាពទាំងឡាយណាដែលអាចប៉ះពាល់ដល់សុវត្ថិភាព ស្ថិរភាព និងសណ្តាប់ធ្នាប់សង្គមឬសកម្មភាពដទៃទៀតដែលអាចបង្កអន្តរាយដល់សន្តិសុខជាតិ ឯកភាពជាតិ វប្បធម៌ និងប្រពៃណីរបស់ប្រជាជនកម្ពុជា។
- ពង្រឹងភាពជាដៃគូរវាងអង្គការដៃគូរបស់ខ្លួន និងអាជ្ញាធរមូលដ្ឋានដោយផ្តល់ព័ត៌មានអំពីសកម្មភាព និងគោលដៅអនុវត្តព្រមទាំងផ្លាស់ប្តូរបទពិសោធន៍ និងរួមគ្នាដោះស្រាយបញ្ហាប្រឈមនានាដែលបានជួបប្រទះ។
- ធ្វើរបាយការណ៍ធមាសស្តីពីសមិទ្ធផលក៏ដូចជាបញ្ហាប្រឈមនានាដែលបានជួបប្រទះ ជូនគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដើម្បីជ្រាប និងដោះស្រាយ ។
- ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សស្តីពីការផ្លាស់ប្តូរណាមួយទាក់ទងនឹងអាសយដ្ឋានអ្នកតំណាង និងនាយកគម្រោងដែលបានចាត់តាំង។
- សេចក្តីសង្ខេបអំពីគម្រោង និងសកម្មភាពជាក់ស្តែងរបស់អង្គការដែនដីមនុស្សហូឡង់ដ៏-ប្រចាំកម្ពុជាសហការជាមួយគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងគោលនយោបាយរបស់អង្គការដែនដីមនុស្សហូឡង់ដ៏-ប្រចាំកម្ពុជា ត្រូវប្រតិបត្តិដូចមានចែងលម្អិតក្នុងឧបសម្ពន្ធ(១) និង (២)។

## ផ្នែកទី៤

## ការដោះស្រាយវិវាទ

**ប្រការ៤.** - រាល់វិវាទដែលអាចកើតឡើងពាក់ព័ន្ធនឹងការបកស្រាយ ឬការអនុវត្តអនុស្សរណៈនេះ គ.ជ.ប.ជ និង អង្គការដែនដីមនុស្សហូឡង់ដ៏-ប្រចាំកម្ពុជា ត្រូវដោះស្រាយតាមរយៈការចរចាដោយសន្តិវិធីរវាងភាគីទាំងពីរ។



k

## ផ្នែកទី៥

## អវសានបញ្ញត្តិ

**ប្រការ៥.** - អនុស្សរណៈយោគយល់នេះ ចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខា និងមានសុពលភាពរយៈពេល ៣(បី) ឆ្នាំ ហើយអាចបន្តសុពលភាពបាន ដោយមានការយល់ព្រមពីភាគីទាំងពីរ។

- ភាគីម្ខាងអាចជូនដំណឹងទៅភាគីម្ខាងទៀតជាលាយលក្ខណ៍អក្សរ ក្នុងពេលណាក៏បាន ប្រសិនបើខ្លួនមានបំណងបញ្ចប់អនុស្សរណៈនេះ ។ អនុស្សរណៈយោគយល់ នឹងត្រូវបញ្ចប់ក្នុងរយៈពេល ៦០ (ហុកសិប)ថ្ងៃគិតចាប់ពីកាលបរិច្ឆេទនៃការទទួលបានការជូនដំណឹង។
- អនុស្សរណៈយោគយល់នេះ ធ្វើឡើងជាពីរច្បាប់ដើម ជាភាសាខ្មែរ និងភាសាអង់គ្លេស ដែលអត្ថបទទាំងពីរភាសាមានតម្លៃស្មើគ្នា។ ក្នុងករណីមិនមានការឯកភាពគ្នាលើការបកស្រាយអត្ថបទទាំងនេះ អត្ថបទជាភាសាខ្មែរត្រូវយកជាគោល ។

ថ្ងៃព្រហស្បតិ៍ ១៤កើត ខែមិគសិរ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២២

**គណៈកម្មាធិការជាតិ**
**ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស**
**អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**

**លោកជំទាវ ជូ ប៊ុនអេង**

**តំណាងអង្គការដែនដីមនុស្សហូឡង់ដ៍**
**ប្រធានគ្រប់គ្រងកម្មវិធីប្រចាំប្រទេសកម្ពុជា**

**លោក គង់ វីឡា**

# ឧបសម្ពន្ធ១

# ព័ត៌មានសង្ខេប

- ឈ្មោះស្ថាប័ន ៖ **អង្គការដៃនដីមនុស្សហូឡង់ដ៏-ប្រចាំកម្ពុជា**
- ប្រភេទស្ថាប័ន ៖ អង្គការអន្តរជាតិ

**បានចុះអនុស្សរណៈជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ចុះថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០២២**

- អាសយដ្ឋានការិយាល័យគម្រោង៖ ផ្ទះលេខ៥៥ ផ្លូវលេខ៣៤៨ សង្កាត់ទួលស្វាយព្រៃ ទី១ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ
- លេខទូរស័ព្ទទំនាក់ទំនង ៖ (៨៥៥) ២៣ ២២២ ៥៥៣, (៨៥៥) ៧៧ ៨១២ ៦៨១
- អ៊ីម៉ែល ៖ s.keo@tdh.nl
- ឈ្មោះគម្រោង ៖ ១. គម្រោងសុវត្ថិភាព និងសិទ្ធិកុមារតាមប្រព័ន្ធអនឡាញ
  ២. គម្រោងគាំទ្រផែនការសកម្មភាពដើម្បីបង្ការ ទប់ស្កាត់ និងឆ្លើយតបការ កេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ
  ៣. គម្រោងលើកកម្ពស់សិទ្ធិកុមារជនជាតិដើមភាគតិច
- ទីតាំងអនុវត្តគម្រោង ៖ រាជធានីភ្នំពេញ និងទូទាំងប្រទេសកម្ពុជា
- អង្គការដៃគូអនុវត្តគម្រោង ៖ អង្គការចំនួន២ ដែលមានសកម្មភាពដើម្បីកុមារ
- ថវិកាអនុវត្តគម្រោង ៖ $ ៦៩៨,០៩១.៧៦

  ( ប្រាំមួយរយកៅសិបប្រាំបីពាន់ កៅសិបមួយដុល្លារ និងចិតសិបប្រាំមួយសេនគត់ )
- កាលបរិច្ឆេទចាប់ផ្តើម ៖ ថ្ងៃទី..........ខែ......................ឆ្នាំ ២០២២
- កាលបរិច្ឆេទបញ្ចប់ ៖ ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២៥
- ចំនួនបុគ្គលិកខ្មែរ ៖ ៨នាក់ (ស្រី៤នាក់)
- ចំនួនបុគ្គលិកបរទេស ៖ ៣នាក់ (ស្រី២នាក់)

K

# ឧបសម្ព័ន្ធ២

**គម្រោងទី១៖ គម្រោងសុវត្ថិភាព និងសិទ្ធិកុមារតាមប្រព័ន្ធអនឡាញ (ពីមុនហៅថាគម្រោងស៊ីតធី)**

ដៃគូអនុវត្ត ៖ អង្គការសកម្មភាពដើម្បីកុមារ និង អង្គការសេរីភាពកម្ពុជា អូស្ត្រាលី

រយៈពេល ៖ ខែតុលាឆ្នាំ២០២២ ដល់ ខែធ្នូ ឆ្នាំ២០២៥

ស្ថានភាព ៖ អនុម័ត

ថវិកាសរុប ៖ $ 570,183.84/527,948 EUR

សង្ខេបពីគម្រោង៖គោលបំណងនៃគម្រោងនេះគឺបង្កើតគំរូអន្តរាគមន៍ជាប្រព័ន្ធ ដើម្បីជាប្រយោជន៍ដល់កុមារកម្ពុជា ដោយមិនគិតអត្តសញ្ញាណយេនឌ័រ ទំនោរផ្លូវភេទ វណ្ណៈ សាសនា ជាតិសាសន៍ និងសមត្ថភាពរបស់ពួកគេ។ហើយគម្រោងនេះជាសមិទ្ធផលពីមុនរបស់ អង្គការ TdH NL ក្នុងការប្រយុទ្ធប្រឆាំងនឹង ការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ (OCSE) នៅក្នុងប្រទេសកម្ពុជា។ គម្រោងនេះមានការចូលរួមពីភាគីពាក់ព័ន្ធចំនួន ៤ សំខាន់៖ (១).កុមារ និងសហគមន៍ (២).ការអនុវត្តច្បាប់ (៣).ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ(៤). វិស័យឯកជន ហើយគម្រោងនេះមានយុទ្ធសាស្ត្រអនុវត្តចំនួន៥៖ ឥទ្ធិពល និង ការតស៊ូមតិ ការពង្រឹងសមត្ថភាព ការផ្សព្វផ្សាយការយល់ដឹង ការកសាងបណ្តាញ និងការរៀនសូត្រ។

**ថវិកាគម្រោងសង្ខេប**

| **សមាសភាគ** | **២០២២ ដល់ ២០២៣** | **២០២៣ ដល់ ២០២៤** | **២០២៤ ដល់២០២៥** |
|---|---|---|---|
| **ចំណាយសម្រាប់ប្រតិបត្តិការ** (មានដូចជាប្រាក់ខែបុគ្គលិក និងចំណាយសម្រាប់ការិយាល័យ)ប្រចាំកម្ពុជា | $ 25,034 | $ 32,473 | $ 33,598 |
| **ចំណាយសម្រាប់ប្រតិបត្តិការ** (មានដូចជាប្រាក់ខែបុគ្គលិក និងចំណាយសម្រាប់ការិយាល័យ) សម្រាប់អង្គការដៃគូរ APLE និង Auscam | APLE $ 6,719 AusCam $ 6,634 | APLE $ 6,721 AusCam $ 7,101 | APLE $ 6,720 AusCam $ 7,615 |
| **ចំណាយផ្ទាល់សម្រាប់គម្រោង** មានដូចជាសវនកម្មហិរញ្ញវត្ថុ កសាងសមត្ថភាព និងការត្រួត ពិនិត្យ និងវាយតម្លៃ | $ 28,100 | $ 32,473 | $ 33,598 |



b

| ថវិកាសម្រាប់ការអនុវត្តសកម្មភាពគម្រោង | | | |
|---|---|---|---|
| **លទ្ធផលទី១៖** កុមារនិងសកម្មក្នុងការចូលរួមដើម្បីឱ្យអ្នកផ្តល់សេវាយកចិត្តដាក់បន្ថែម និង កុមារយល់ដឹងពីរយន្តការរាយការណ៍ពីការរំលោភផ្លូវភេទតាមអនឡាញ | $58,582.44 | $52,073.28 | $48,529.80 |
| **លទ្ធផលទី២៖** ផ្តល់វគ្គបណ្តុះបណ្តាលដល់បុគ្គលិកក្រុមហ៊ុនអ៊ីនធឺណិត ប្រព័ន្ធផ្សព្វផ្សាយ និង ក្រុមហ៊ុនបច្ចេកវិទ្យាពី ការរំលោភបំពានផ្លូវភេទកុមារតាមអនឡាញ | $18,934.56 | $11,794.80 | $10,995.48 |
| **លទ្ធផលទី៣៖** អ្នកអនុវត្តច្បាប់ទាំងថ្នាក់ជាតិ និងក្រោមជាតិនិងបង្កើនការសហការគ្នាក្នុងការដោះស្រាយបញ្ហាការរំលោភបំពានផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញ ឱ្យកាន់តែមានប្រសិទ្ធភាព និងមានចំណេះដឹងបន្ថែមទៀតក្នុងការ ឆ្លើយតបបញ្ហាការរំលោភបំពានផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញ | $15,085.44 | $1,969.92 | $1,969.92 |
| **លទ្ធផលទី៤៖** អាជ្ញាធរថ្នាក់ជាតិ និងក្រោមជាតិនិងកំណត់ពីចំណុចខ្វះខាតក្រមព្រហ្មទណ្ឌ គោលនយោបាយ និង សេចក្តីណែនាំផ្សេងៗ ទាក់ទងនិងបញ្ហាការរំលោភបំពានផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញ | $24,420.96 | $56,695.68 | $49,065.48 |
| **ថវិកាសរុប** | $183,510.40 | $201,301.68 | $192,091.68 |

*អត្រាប្តូរប្រាក់ ១អឺរ៉ូ = ១.២ ដុល្លារអាមេរិក ( អត្រាប្តូរប្រាក់អាចមានការប្រែប្រួលបន្ទាប់ពីឆ្នាំ២០២២)*

**គម្រោងទី២៖ គម្រោងគាំទ្រផែនការសកម្មភាពដើម្បីបង្ការ ទប់ស្កាត់ និងឆ្លើយតបការ កេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ**

ដៃគូអនុវត្ត ៖ អង្គការសកម្មភាពដើម្បីកុមារ

រយៈពេល ៖ ខែមេសា ដល់ ខែធ្នូ ឆ្នាំ២០២២

ស្ថានភាព ៖ អនុម័ត

ថវិកាសរុប ៖ $ 93,497 / 77,914 EUR



៤

សង្ខេបពីគម្រោង៖ គម្រោងនេះមានគោលបំណងបង្កើនការបង្ការ ទប់ស្កាត់ការរំលោភបំពានផ្លូវភេទលើកុមារនៅតាមប្រព័ន្ធអនឡាញ និងបង្កើនការផ្តល់សេវាដល់កុមារដែលរងគ្រោះ ដោយជំរុញឲ្យមានការសហការរវាងអាជ្ញាធរ និងវិស័យឯកជន ដោយផ្តោតលើះការកសាងសមត្ថភាព តាមដាន និងវាយតម្លៃ ការបង្កើតសេចក្តីណែនាំ ស្តីពីកិច្ចការពារកុមារតាមប្រព័ន្ធអនឡាញ សកម្មភាពសិក្ខាសាលាជាមួយកុមារ បុគ្គលិកផ្នែកសង្គម និងមន្ត្រីរាជរដ្ឋាភិបាលដូចជាក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) និងមន្ទីរកិច្ចការនារីនៅក្នុងរាជធានីភ្នំពេញ និងខេត្តសៀមរាប។

**ថវិកាគម្រោងសង្ខេប**

| **សមាសភាគ** | **ឆ្នាំ២០២២ ដល់ ២០២២** |
|---|---|
| **ចំណាយសម្រាប់ប្រតិបត្តិការ** (មានដូចជាប្រាក់ខែបុគ្គលិក និងចំណាយសម្រាប់ការិយាល័យ) ប្រចាំកម្ពុជា | $ 9,497 |
| **ចំណាយសម្រាប់ប្រតិបត្តិការ** (មានដូចជាប្រាក់ខែបុគ្គលិក និងចំណាយសម្រាប់ការិយាល័យ) សម្រាប់អង្គការដៃគូ ( APLE) | $ 3,523 |
| **ចំណាយផ្ទាល់សម្រាប់គម្រោង** មានដូចជា សវនកម្មហិរញ្ញវត្ថុ កសាងសមត្ថភាព និង ការត្រួតពិនិត្យ និងវាយតម្លៃ | $ 8,315 |

| **ថវិកាសម្រាប់ការអនុវត្តសកម្មភាពគម្រោង** | |
|---|---|
| **លទ្ធផលទី១៖** រដ្ឋាភិបាលពង្រឹងការអនុវត្តច្បាប់ការពារសិទ្ធិកុមារ និង គោលនយោបាយផ្សេងៗទាក់ទង នឹងការការពារការរំលោភបំពានផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ និងវិស័យឯកជននិងចូលរួមអនុវត្តដោយមានប្រសិទ្ធភាព។ | $ 25,355 |
| **លទ្ធផលទី២៖** ប្រព័ន្ធរាយការណ៍ និងផែនការរបស់រាជរដ្ឋាភិបាល ដើម្បីឆ្លើយតបការរំលោភបំពានផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញនិងមានភាពកាន់តែប្រសើរឡើង | $ 26,269 |
| **លទ្ធផលទី៣៖** កសាងសមត្ថភាពអ្នកផ្តល់សេវាដល់ជនរងគ្រោះពីការរំលោភបំពានផ្លូវភេទតាមប្រព័ន្ធអនឡាញឲ្យអនុវត្តការថែទាំដោយផ្អែកលើការប៉ះទង្គិចផ្លូវចិត្ត និងការយកចិត្តទុកដាក់ចំពោះជនរងគ្រោះ | $ 20,537 |
| **ថវិកាសរុប** | $ 93,496 |

***អត្រាប្តូរប្រាក់ ១អឺរ៉ូ = ១.២ ដុល្លារអាមេរិក***

**គម្រោងទី៣៖ គម្រោងលើកកម្ពស់សិទ្ធិកុមារជនជាតិដើមភាគតិច**

ដៃគូអនុវត្ត ៖ អនុវត្តដោយខ្លួនឯង

រយៈពេល ៖ ខែកក្កដាឆ្នាំ២០២២ ដល់ ខែធ្នូ ឆ្នាំ២០២២

ស្ថានភាព ៖ អនុម័ត

ថវិកាសរុប ៖ 27,691 / 22,886 EUR

សង្ខេបពីគម្រោង៖ គោលបំណងគម្រោងនេះគឺដើម្បីលើកកម្ពស់ការចូលរួម និងសិទ្ធិរបស់កុមារនៅក្នុងការអភិវឌ្ឍមូលដ្ឋាន។ គោលដៅអនុវត្តគម្រោងគឺនៅក្នុងស្រុកពេជ្រាដា ខេត្តមណ្ឌលគិរី ហើយសកម្មភាពគម្រោង មានការចូលរួមពីកុមារ យុវជន អាណាព្យាបាល អាជ្ញាធរ ដោយសហការជាមួយបណ្តាញការពារកុមារឃុំ។

**ថវិកាគម្រោងសង្ខេប**

| **សមាសភាគ** | **ឆ្នាំ២០២២ ដល់ ២០២២** |
|---|---|
| **ចំណាយសម្រាប់ប្រតិបត្តិការ** (មានដូចជាប្រាក់ខែបុគ្គលិក និងចំណាយសម្រាប់ការិយាល័យ)ប្រចាំកម្ពុជា | $ 4,689 |
| **ចំណាយផ្ទាល់សម្រាប់គម្រោង** មានដូចជា សវនកម្មហិរញ្ញវត្ថុ កសាងសមត្ថភាព និង ការត្រួតពិនិត្យ និងវាយតម្លៃ | $4,529 |

| **ថវិកាសម្រាប់ការអនុវត្តសកម្មភាពគម្រោង** | |
|---|---|
| **លទ្ធផលទី១៖** កុមារ និងយុវជនដឹងពីសិទ្ធិការចូលរួម និង អភិវឌ្ឍន៍ | $ 8,344 |
| **លទ្ធផលទី២៖** អាជ្ញាធរមូលដ្ឋាន គាំទ្រការចូលរួមរបស់កុមារដោយដាក់បញ្ចូលបញ្ហារបស់កុមារទៅក្នុងផែនការរបស់ ខេត្ត ស្រុក ឃុំ | $ 10,130 |
| **ថវិកាសរុប** | $ 27,692 |

***អត្រាប្តូរប្រាក់ ១អឺរ៉ូ = ១.២ ដុល្លារអាមេរិក***

៥